**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ :** ៧៤៣ **អយក** ស៧៤៣

China

## សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ ក្រោយឧត្តមសិក្សា នៅសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំសិក្សា ២០០៦-២០០៧

**យោង** : កំណត់ទូត (២០០៦) លេខ ០២៩ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

## ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងថា រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់អាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សា ចំនួន ០៣ កន្លែងដល់ពលរដ្ឋកម្ពុជា ដើម្បីទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំសិក្សា ២០០៦-២០០៧ ។

សោហ៊ុយធ្វើដំណើរទៅ-មក ជាបន្ទុករបស់សាមីជន ឯការចំណាយផ្សេងៗលើការស្នាក់នៅ ការសិក្សា ប្រាក់អាហារូបករណ៍ ជាបន្ទុករបស់រដ្ឋាភិបាលចិន ។

**I-មុខជំនាញ**

**ដូចជា :**

វិទ្យាសាស្ត្រ វិស្វកម្ម កសិកម្ម សេដ្ឋកិច្ច ការគ្រប់គ្រងពាណិជ្ជកម្ម វេជ្ជសាស្ត្រ ពត៌មានវិទ្យា ។ល។

**II-លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខជន :**

បេក្ខជនទាំងពីរភេទត្រូវ :

-មានសញ្ជាតិខ្មែរ

-មានអាយុមិនលើសពី ៣៥ ឆ្នាំ

-មានសញ្ញាប័ត្របរិញ្ញាប័ត្រ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ

-មានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

-ចេះភាសាអង់គ្លេសជ្រៅជ្រះ ( អាចនិយាយ និងសរសេរបាន)

**III-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ :**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង ១៦:០០ នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាស័យដ្ឋាន អគារលេខ ២៣

ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ( ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរា ) ។

**IV-កាលបរិច្ឆេទប្រឡង :**

ក្រសួងនឹងរៀបចំការប្រឡងនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ។ មណ្ឌលប្រឡង នឹងជំរាបជូនពេលក្រោយ ។

**V-វិញ្ញាសាប្រឡងមាន :**

-វប្បធម៌ទូទៅ រយៈពេល ១ ម៉ ៣០នាទី

-ភាសាអង់គ្លេស រយៈពេល ១ ម៉ ៣០នាទី

**សំណុំឯកសារដែលត្រូវបំពេញមាន**

១-ពាក្យសុំអាហារូបករណ៍ មួយច្បាប់ ( មានគំរូ )

២-ជីវប្រវត្តិសង្ខេប ពីរច្បាប់ ( មានគំរូ )

៣-រូបថត 4 X 6 ២សន្លឹក ( ពណ៌ធម្មជាតិ ថតថ្មី១ )

៤-សញ្ញាប័ត្របរិញ្ញាប័ត្រ ឬសញ្ញាប័ត្រមានតំលៃស្មើ "ថតចំលង ០១ច្បាប់"

**( ភ្ជាប់មកជាមួយនូវច្បាប់ដើមដើម្បីផ្ទៀងផ្ទាត់ )** ។

៥-សេចក្តីបញ្ជាក់ពីគ្រឹះស្ថានឧត្តមសិក្សា "ចំពោះបេក្ខជនជានិស្សិតកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា" ។

ផ្អែកលើលទ្ធផលប្រឡងក្រសួងអប់រំ យុវជន និងកីឡា នឹងជ្រើសរើសយកបេក្ខជនថ្នាក់ក្រោយឧត្តមសិក្សាចំនួន០៩ នាក់ ដើម្បីបញ្ជូនទៅស្ថានទូតចិនធ្វើសំភាសន៍ជាភាសាអង់គ្លេសជាបន្តបន្ទាប់ទៀត ។

ជាចុងក្រោយ រដ្ឋាភិបាលចិននឹងពិនិត្យសំរេចលើសំណុំលិខិតបេក្ខជន ដើម្បីជ្រើសរើសយកចំនួន ០៣នាក់ សំរាប់ថ្នាក់ក្រោយឧត្តមសិក្សា ។

ចំពោះពត៌មានលំអិតផ្សេងៗទៀត សូមអញ្ជើញទាក់ទងដោយផ្ទាល់នៅការិយាល័យអាហារូបករណ៍ និង កម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អគារលេខ ២៣, ផ្លូវលេខ ៣៦០, សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ( ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរា ) ។

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦

**ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**មិត ខាន់**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅភ្នំពេញ

*"ដើម្បីជូនជ្រាបជាពត៌មាន"*

-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

-គ្រប់សាលាខេត្ត-ក្រុង

-គ្រប់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង

*"ដើម្បីជួយផ្សព្វផ្សាយ"*

-កាលប្បវត្តិ-ឯកសារ